ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ៤២៧៩ លជណ.អក.អជ

សេចក្តីជូនដំណឹង

អគ្គិសនីកម្ពុជាមានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : ដើម្បីអនុវត្តការងារជួសជុល ថែទាំ និងផ្លាស់ប្តូរបរិក្ខារប្រព័ន្ធបណ្តាញចែកចាយ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដោយមូលហេតុដូចខាងក្រោម :

១. ថ្ងៃសុក្រទី២៣ ខែឧសភា ឆ្នាំ២០១៤ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី (១)ចាប់ពីម៉ោង០៩ម៉ោ០០ ដល់ម៉ោង១៣ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ ចាប់ពីភូមិស្ពានខ្ពស់ ក្នុងសង្កាត់គីឡូម៉ែត្រលេខ៦ រហូតដល់ភូមិ៣ ក្នុងសង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ និង (២)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៧ម៉០០ នៅតំបន់ភ្លើងលេខ P776, P1155, P1222 ស្ថិតនៅក្នុងសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារ និងរុះរើគន្លងខ្សែបណ្តាញបង្កលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវលេខ១០០៣ ។

២. ថ្ងៃសៅរ៍ទី២៤ ខែឧសភា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៣ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវទំនប់អូស្រ្តាលី ចាប់ពីភូមិត្នោតជ្រុំ ក្នុងសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រហូតដល់គល់ស្ពានចំការដូង រួមទាំងតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជើងឯក ចាប់ពីគល់ស្ពានចំការដូង រហូតដល់ភូមិព្រែកប្រណាក់ ក្នុងសង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

៣. ថ្ងៃសុក្រទី២៣ និងថ្ងៃសៅរ៍ទី២៤ ខែឧសភា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅ (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិដើមគរ ក្នុងសង្កាត់ព្រែកតាសេក ខណ្ឌឫស្សីកែវ និង (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវវែងស្រេង ចាប់ពីភូមិទ្រា ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រហូតដល់ភូមិទួលពង្រ ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារ និងរុះរើគន្លងខ្សែបណ្តាញបង្កលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវវែងស្រេង។

៤. ថ្ងៃអាទិត្យទី២៥ ខែឧសភា ឆ្នាំ២០១៤ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី (១)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៣ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិព្រៃព្រីងខាងត្បូង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រួមទាំងតំបន់ភ្លើងលេខ P876 ស្ថិតនៅភូមិផ្សារលិច២ ក្នុងសង្កាត់ព្រែកព្នៅ ខណ្ឌសែនសុខ និង (២)ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នៅតំបន់ភ្លើងលេខ ប.ត019 ស្ថិតនៅតាមបណ្តោយផ្លូវស្រុកទ្រាំង ក្នុងសង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដើម្បីតម្លើង និងផ្លាស់ប្តូរបរិក្ខារបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាពត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី........២១.....ខែ..ឧសភា..ឆ្នាំ២០១៤

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា

កែវ_រតនៈ